# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

# ការរៀបចំ និងការប្រព្រឹត្តទៅរបស់
# ក្រុមប្រឹក្សាយោបល់នៃកម្មវិធីរេដបូកកម្ពុជា

រាជធានីភ្នំពេញ
ឆ្នាំ ២០១៥

# ក្រុមប្រឹក្សាយោបល់នៃកម្មវិធីរេដបូកកម្ពុជា

- បានឃើញឯកសារគម្រោងថ្នាក់ជាតិ យូ អិន រេដ (Cambodia UN-REDD National Program) ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១១
- បានឃើញឯកសារគម្រោងមូលនិធិដៃគូកាបូនព្រៃឈើ (Forest Carbon Partnership Facility REDD+ Readiness Project) ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ ២០១៣
- បានឃើញផែនទីបង្ហាញផ្លូវរេដបូកកម្ពុជា (Cambodia REDD+ Roadmap) ចុះថ្ងៃទី ៤-៥ ខែ វិច្ឆិកា ឆ្នាំ ២០១០
- បានឃើញភាពចាំបាច់របស់ ក្រុមប្រឹក្សាយោបល់នៃកម្មវិធីរេដបូកកម្ពុជា បានបង្កើតការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាយោបល់នៃកម្មវិធីរេដបូកកម្ពុជា ដូចតទៅៈ

# ប្រការ ១៖ សាវតា និងគោលបំណង

កម្មវិធីរេដបូកកម្ពុជា (Cambodia REDD+ National Program) ត្រូវបានចុះហត្ថលេខាដាក់ឲ្យអនុវត្តរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១១ ហើយបានផ្តួចផ្តើមឲ្យមានការចូលរួម និងការប្រឹក្សាយោបល់ពីភាគីអ្នកពាក់ព័ន្ធក្នុងដំណើរការត្រៀមខ្លួនរួចជាស្រេចសម្រាប់កម្មវិធីរេដបូកកម្ពុជា ជាពិសេស បានលើកឡើងការបង្កើតក្រុមប្រឹក្សាយោបល់នៃកម្មវិធីរេដបូកកម្ពុជា ដែលមានតំណាងមកពីគ្រប់ភាគីពាក់ព័ន្ធចូលរួម ដើម្បីផ្តល់ជាវេទិកាតំណាងឲ្យទស្សនៈក្នុងការផ្តល់អនុសាសន៍ និងសំណើ ជូនដល់ក្រុមការងាររេដបូកកម្ពុជា (**Cambodia REDD+ Taskforce**)។

ឯកសារផែនទីបង្ហាញផ្លូវរេដបូកកម្ពុជា (**Cambodia REDD+ Roadmap**) គឺជាផែនការជាតិសម្រាប់ជួយរាជរដ្ឋាភិបាលកម្ពុជាឈានឆ្ពោះទៅមុខក្នុងការត្រៀមខ្លួនរួចជាស្រេច ក្នុងការអនុវត្តរេដបូក (**REDD+ Readiness**)។ ដោយផ្អែកតាមការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធនៅចុងឆ្នាំ ២០០៩ និងដើមឆ្នាំ ២០១០ ស្ថាប័នរដ្ឋបានក្រុមការងាររេដបូកកម្ពុជា ដែលមានសមាជិកពីក្រសួងពាក់ព័ន្ធនៅឆ្នាំ ២០១០។ ដោយផ្អែកលើការងារផ្តួចផ្តើមខាងលើនេះ ក្រុមប្រឹក្សាយោបល់រេដបូក នៃកម្មវិធី រេដបូកកម្ពុជា (**REDD+ Consultation Group**) មានគោលបំណងបង្កើតឡើងដើម្បីផ្តល់ប្រឹក្សាយោបល់ឲ្យក្រុមការងាររេដបូកកម្ពុជា តាមរយៈលេខាធិការដ្ឋាននៃក្រុមការងាររេដបូកកម្ពុជា និងជាវេទិកាតំណាងឲ្យទស្សនៈរបស់

ភាគីពាក់ព័ន្ធដែលមានតំណាងមកពីអង្គការសង្គមស៊ីវិល វិស័យឯកជន គ្រឹះស្ថានអប់រំ បណ្តាញសហគមន៍ព្រៃឈើ សហគមន៍នេសាទ សហគមន៍តំបន់ការពារធម្មជាតិ និងក្រុមជនជាតិដើមភាគតិច។

# ប្រការ ២៖ សមាជិកភាព និងលក្ខណៈវិនិច្ឆ័យនៃក្រុមប្រឹក្សាយោបល់នៃកម្មវិធីរេដបូកកម្ពុជា

## ២.១. សមាជិកភាព

ក្រុមប្រឹក្សាយោបល់នេះមានសមាជិកជាតំណាងមកពីស្ថាប័ន និងសហគមន៍ចំនួន៩ ដែលបាន នឹងកំពុងអនុវត្តការងារពាក់ពន្ធ័នឹងវិស័យព្រៃឈើ និងធនធានធម្មជាតិ ដែលទទួលស្គាល់ដោយ រាជរដ្ឋាភិបាលប្រទេសកម្ពុជា និងដែលមានសមាជិកចំនួន ១៨ នាក់ដូចខាងក្រោម៖

១. អង្គការមិនមែនរដ្ឋាភិបាលជាតិ (០២រូប)
២. អង្គការមិនមែនរដ្ឋាភិបាលជាតិអន្តរជាតិ (០២រូប)
៣. អង្គការសង្គមស៊ីវិលថ្នាក់ខេត្ត (០២រូប)
៤. ជនជាតិដើមភាគតិច (០២រូប)
៥. គ្រឹះស្ថានអប់រំ (០២រូប)
៦. វិស័យឯកជន (០២រូប)
៧. បណ្តាញសហគមន៍ព្រៃឈើ (០២រូប)
៨. បណ្តាញសហគមន៍នេសាទ (០២រូប) និង
៩. បណ្តាញសហគមន៍តំបន់ការពារធម្មជាតិ (០២រូប)។

## ២.២. លក្ខណៈ វិនិច្ឆ័យសម្រាប់ជ្រើសរើសសមាជិកនៃក្រុមប្រឹក្សាយោបល់

បេក្ខជនដែលអាចត្រូវបានជ្រើសរើសជាសមាជិកក្រុមប្រឹក្សាយោបល់នៃកម្មវិធីរេដបូកកម្ពុជាត្រូវមានលក្ខណៈ វិនិច្ឆ័យដូចខាងក្រោមនេះ៖

- ត្រូវតែជាអ្នកតំណាងឲ្យក្រុមណាមួយខាងលើ

- ត្រូវមានការយល់ដឹងឬបទពិសោធន៍ដែលពាក់ព័ន្ធ ដូចជាជនជាតិដើមភាគតិច សហគមន៍មូលដ្ឋាន ព្រៃឈើ ជលផល បរិស្ថាន ការប្រែប្រួលអាកាសធាតុ កសិកម្ម និងធនធានធម្មជាតិ
- ត្រូវតែទទួលបាននូវការតែងតាំងពីសាមីស្ថាប័ន ឬបណ្តាញ របស់ខ្លួន
- ត្រូវមានការតាំងចិត្តខ្ពស់ក្នុងការចូលរួមចំណែកក្នុងទំនួលខុសត្រូវរបស់សមាជិកក្រុម
- មានទំនាក់ទំនង និងប្រាស្រ័យទាក់ទងល្អ ជំនាញក្នុងសម្របសម្រួល និង អន្តរបុគ្គល
- យល់ដឹងពីគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាចំពោះវិស័យដែលពាក់ព័ន្ធខាងលើ
- ចេះភាសាខ្មែរ ទាំងនិយាយ អាន និងសរសេរ
- ចេះភាសាអង់គ្លេសទៀតកាន់តែប្រសើរ
- ស្ត្រីត្រូវបានផ្តល់អាទិភាព និងលើកទឹកចិត្តឲ្យចូលរួម

# ប្រការ ៣៖ រចនាសម្ព័ន្ធ និងការប្រព្រឹត្តនៃក្រុមប្រឹក្សាយោបល់នៃកម្មវិធីរេដបូកកម្ពុជា

## ៣.១. រចនាសម្ព័ន្ធ

ក្រុមប្រឹក្សាយោបល់នេះមានរចនាសម្ព័ន្ធគ្រប់គ្រងដូចខាងក្រោម៖

### ៣.១.១. គណៈកម្មការ

គណៈកម្មការនេះមានសមាសភាពដូចខាងក្រោម៖

១. ប្រធាន (១រូប)

២. អនុប្រធាន (១រូប)

៣. លេខា (១រូប)

### ៣.១.២. សមាជិក

ក្រុមប្រឹក្សាយោបល់នេះមានសមាជិក១៥រូប ដោយមិនគិតសមាជិកគណៈកម្មការខាងលើ។

### ៣.១.៣. ការជ្រើសរើសសមាជិកគណៈកម្មការ

- សមាជិកគណៈកម្មការនេះមានអាណត្តិសម្រាប់ រយៈពេលមួយឆ្នាំហើយដែលត្រូវជ្រើសរើសឡើងវិញនូវរៀងរាល់ការប្រជុំសាមញ្ញលើកទីមួយនៃឆ្នាំ ឬការប្រជុំណាមួយផ្សេងទៀតបើមានការចាំបាច់។ និតិវិធីនៃការជ្រើសរើស សមាជិកគណៈកម្មការត្រូវសម្រេចឡើងដោយអង្គប្រជុំនោះ។
- បញ្ជូនសមាសភាពសមាជិកគណៈកម្មការជូន ប្រធាន លេខាធិការដ្ឋានវេជបុកជូនជ្រាបព័ត៌មាន

### ៣.១.៤.ការជ្រើសរើសសមាជិក

ការជ្រើសរើសសមាជិកថ្មីជំនួសសមាជិកដែលបានបាត់បង់សមាជិកភាពអាចធ្វើបាននៅគ្រប់ការប្រជុំក្រុមប្រឹក្សាយោបល់ ហើយនិតិវិធីនៃការជ្រើសរើស សមាជិកថ្មីនេះ ត្រូវសម្រេចឡើងដោយអង្គប្រជុំនោះ។

### ៣.១.៥. ការបញ្ចប់សមាជិកភាព

សមាជិកភាពរបស់សមាជិកគណៈកម្មការ ឬសមាជិកក្រុមប្រឹក្សាយោបល់ ត្រូវបានបញ្ចប់ក្នុងលក្ខ័ណ្ឌណាមួយដូចខាងក្រោម៖

- ការសុំលាឈប់
- ការបញ្ឈប់ដោយការសម្រេចរបស់ក្រុមប្រឹក្សាយោបល់
- មរណភាព

### ៣.១.៦. និតិវិធីនៃការលាឈប់ និងការបញ្ឈប់

- សមាជិកដែលស្នើលាឈប់ពីក្រុមពិគ្រោះយោបល់ ត្រូវសរសេរលិខិតជាលាយលក្ខណ៍អក្សរជូនមកប្រធានគណៈកម្មការ ដើម្បីទុកជាឯកសារយោង។
- សមាជិកក្រុមប្រឹក្សាយោបល់ដែលអវត្តមានក្នុងការប្រជុំចំនួនបី (៣) ដងជាប់គ្នា ដោយមិនមានបញ្ជាក់មូលហេតុ ឬមិនបានបញ្ជូនតំណាងរបស់ខ្លួនមកចូលរួមប្រជុំជំនួស នឹងត្រូវលើកមកពិភាក្សាក្នុងអង្គប្រជុំបន្ទាប់ដើម្បីសម្រេច។ ការសម្រេចរបស់អង្គប្រជុំត្រូវសរសេរឲ្យបានច្បាស់លាស់នៅក្នុងកំណត់ហេតុរបស់ការប្រជុំ។

**៣.២. តួនាទី និងភារកិច្ច៖** សមាជិកនៃក្រុមប្រឹក្សាយោបល់ មានតួនាទី និងភារកិច្ចដូចខាងក្រោម

**៣.២.១. ប្រធាន**

ប្រធានក្រុមប្រឹក្សាយោបល់ មានតួនាទី និងភារកិច្ចចំបងៗដូចខាងក្រោម៖

- ជាតំណាងឲ្យក្រុមប្រឹក្សាយោបល់វេជបូក ក្នុងការធ្វើទំនាក់ទំនងជាមួយលេខាធិការដ្ឋានវេជបូក ឬភាគីពាក់ព័ន្ធផ្សេងទៀតដើម្បីបម្រើឲ្យការងារវេជបូក។
- រៀបចំយុទ្ធសាស្ត្រ ផែនការសកម្មភាព សំណើរគម្រោង របៀបវារៈ និងកិច្ចការពាក់ព័ន្ធនៃការប្រជុំ កោះអញ្ជើញសមាជិកក្រុមប្រឹក្សាយោបល់ចូលរួមប្រជុំ ក្រោមការសម្របសម្រួលរបស់លេខាធិការដ្ឋានវេជបូក។
- សហការជាមួយសហប្រធាន ដឹកនាំកិច្ចប្រជុំទាំងឡាយរបស់ក្រុមប្រឹក្សាយោបល់
- ចុះហត្ថលេខាលើកំណត់ហេតុបន្ទាប់ពីទទួលបាននូវការឯកភាពពីសមាជិកទាំងអស់ និងបញ្ជូនទៅ លេខាធិការដ្ឋានវេជបូក។
- សម្របសម្រួល និងពិនិត្យចុងក្រោយទៅលើអនុសាសន៍ សកម្មភាពអនុវត្តន៍ និងរាល់ឯកសារការងាររបស់ក្រុមប្រឹក្សាយោបល់ ដែលបានពិភាក្សា ឬដាក់ជូនដោយសមាជិកក្រុមនីមួយៗ មុននឹងដាក់បញ្ជូនទៅលេខាធិការដ្ឋានវេជបូក ដើម្បីដាក់បញ្ជូនបន្តទៅក្រុមការងារវេជបូក។
- ធានានូវប្រតិបត្តិការជាទូទៅរបស់សមាជិក ក្រុមប្រឹក្សាយោបល់ ឲ្យស្របទៅតាមគោលការណ៍ និងនីតិវិធីរបស់ខ្លួន។
- ពិនិត្យ និងអនុម័តចុងក្រោយលើរបាយការណ៍វឌ្ឍនភាព របាយការណ៍ប្រចាំឆ្នាំ និងរបាយការណ៍ទាំងឡាយ ដែលជាប់ពាក់ព័ន្ធនឹងការអនុវត្តរបស់ក្រុមប្រឹក្សាយោបល់។
- សិក្សា និងស្វែងរកវិធីសាស្ត្រ ដើម្បីដោះស្រាយបញ្ហា តម្រង់ទិស និងគ្រប់គ្រងដំណើរការទាំងឡាយរបស់ក្រុមប្រឹក្សាយោបល់។

**៣.២.២. អនុប្រធាន**

- តាមដានការអនុវត្តផែនការសកម្មភាពវេជបូករបស់សមាជិកក្រុមប្រឹក្សាយោបល់។
- ត្រូវបំពេញរាល់ភារកិច្ច និងការទទួលខុសត្រូវទាំងអស់ របស់ប្រធានក្រុមប្រឹក្សាយោបល់ក្នុងករណី ប្រធានអវត្តមាន។
- ចូលរួម និងតំណាងក្នុងកិច្ចប្រជុំទាំងឡាយ ដែលពាក់ព័ន្ធនឹងការអនុវត្ត និងសកម្មភាពរបស់ក្រុមប្រឹក្សាយោបល់។

- ជួយ និងសម្របសម្រួលនូវរាល់ភារកិច្ចដែលប្រធានស្នើសុំ។

៣.២.៣. លេខា

- ជួយសម្របសម្រួលកិច្ចការងាររបស់ប្រធាន និងអនុប្រធាន ដោយធ្វើការពិគ្រោះយោបល់ជាមួយ សមាជិកក្រុមប្រឹក្សាយោបល់ ដើម្បីជួយដល់ការគ្រប់គ្រងដំណើរការរបស់ក្រុមប្រឹក្សាយោបល់ឲ្យ មានភាពប្រសើរ និងទទួលបានជោគជ័យ។
- ជួយប្រធានក្រុមប្រឹក្សាយោបល់ក្នុងការរៀបចំកោះហៅកិច្ចប្រជុំនិងសរសេររបាយការណ៍ ឬកំណត់ហេតុ នៃអង្គប្រជុំរបស់ក្រុមប្រឹក្សាយោបល់រេដបូក ដោយមានការជួយពីសមាជិករបស់ក្រុមប្រឹក្សាយោបល់ និងសហការជាមួយលេខាធិការដ្ឋានរេដបូក។
- ជួយដល់ការងារទាំងឡាយណាដែលបានស្នើសុំដោយប្រធាន អនុប្រធាន ឬ សមាជិកក្រុមប្រឹក្សាយោបល់ ដើម្បីរក្សាភាពរលូននៅក្នុងការអនុវត្តការងារ និងឲ្យត្រឹមត្រូវ នៅពេលដែលប្រធាន និង អនុប្រធានអវត្តមាន។

៣.២.៤. សមាជិកក្រុមប្រឹក្សាយោបល់ (រួមបញ្ចូលទាំងប្រធាន អនុប្រធាន និងលេខា)

- សមាជិកក្រុមប្រឹក្សាយោបល់ ត្រូវជូនដំណឹងមកប្រធាន ក្នុងរង្វង់មួយ (០១) សប្តាហ៍ចំពោះរាល់ការផ្លាស់ប្តូរទាំងឡាយណា ឬ រាល់វត្តមានឬអវត្តមានរបស់ខ្លួនក្នុងកិច្ចប្រជុំណាមួយ។
- ចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាយោបល់។
- ប្រមូល សង្ខេប និងរៀបចំយោបល់ សរសេរព្រាងរបាយការណ៍ និងសំណើសេចក្តីសម្រេចចិត្តទៅលើឯកសារ និងការអនុវត្តរបស់ក្រុមការងាររេដបូកកម្ពុជា ដែលបានមកពីក្រុមនីមួយៗ ដែលខ្លួនតំណាងឲ្យ។
- ចូលរួមព្រាង យុទ្ធសាស្ត្រ ផែនការសកម្មភាព សំណើរគម្រោង របាយការណ៍របៀបវារៈ និងទំនាក់ទំនងផ្សេងៗ។
- ជួបប្រជុំរៀងរាល់ពីរខែម្តង ឬទៅតាមតម្រូវការចាំបាច់ ជាមួយលេខាធិការដ្ឋានរេដបូក ក្រុមការងាររេដបូក និងអង្គការភាគីចូលរួមពាក់ព័ន្ធនានា ដើម្បីពិភាក្សាលើដំណើរការត្រៀមលក្ខណៈសម្រាប់ រេដបូកកម្ពុជា។

- សម្របសម្រួលនិងចែករំលែកព័ត៌មានដែលពាក់ព័ន្ធនឹងការអភិវឌ្ឍរេដបូកនៅកម្ពុជា ទៅដល់សមាជិកក្រុមប្រឹក្សាយោបល់ក្រុម(ប្រឹក្សាយោបល់នីមួយៗ)ដែលខ្លួនតំណាងឲ្យ ក្រុមការងាររេដបូកលេខាធិការដ្ឋានរេដបូកនិងសមាជិកភាគីចូលរួមពាក់ព័ន្ធដទៃទៀត។
- ផ្តល់យោបល់ ឬ សំណើជាលាយលក្ខណ៍អក្សរដល់ក្រុមការងាររេដបូក ពីបញ្ហាកង្វល់នានា តាងនាម ឲ្យក្រុមនីមួយៗដែលខ្លួនតំណាងឲ្យ។
- ផ្តល់យោបល់ជាក់លាក់លើបញ្ហាសំខាន់ៗ ដូចជា៖ ការប្រឹក្សាយោបល់ ការចូលរួម ឬ ប្រព័ន្ធធានាសុវត្ថិភាពសង្គម និងបរិស្ថាន។
- ធ្វើការពិភាក្សាជាមួយក្រុមតំណាងទាំងអស់នៃសមាជិកក្រុមប្រឹក្សាយោបល់ លើមតិយោបល់ ព័ត៌មាន អនុសាសន៍ និង/ឬ សំណើសុំពីក្រុមនីមួយៗ មុនដាក់ជូនទៅក្រុមការងាររេដបូក តាមរយៈ លេខាធិការដ្ឋានរេដបូក។
- ចូលរួមជាសមាជិកក្រុមការងារបច្ចេកទេសរេដបូកក្នុងនាមជាតំណាងឲ្យក្រុមប្រឹក្សាយោបល់ដើម្បីគាំទ្រដល់ការប្រឹក្សាយោបល់ និងសកម្មភាពលើកកម្ពស់ការយល់ដឹងពីដំណើរការត្រៀមលក្ខណៈសម្រាប់ការអនុវត្តរេដបូកនៅកម្ពុជា។

# ប្រការ ៤៖ ការប្រជុំរបស់ក្រុមប្រឹក្សាយោបល់នៃកម្មវិធីរេដបូកកម្ពុជា

៤.១. កិច្ចប្រជុំ

៤.១.១.រាល់ពេលប្រជុំ សាមញ្ញ វិសាមញ្ញ និងប្រចាំឆ្នាំ របស់ក្រុមប្រឹក្សាយោបល់នេះ ត្រូវមានការចូលរួមពីប្រធានលេខាធិការដ្ឋាននៃក្រុមការងាររេដបូកកម្ពុជា (Secretariat of Cambodia REDD+ Taskforce) ជាសហប្រធាននៃអង្គប្រជុំនោះ។

**៤.១.២. កូរ៉ុម ការសម្រេច និងកំណត់ហេតុ**

ការប្រជុំទាំងអស់របស់ក្រុមប្រឹក្សាយោបល់អាចធ្វើទៅបានលុះត្រាតែមានការចូលរួមពីសមាជិកយ៉ាងតិចហាសិបភាគរយបូកមួយ(៥០%បូក១) ហើយការសម្រេចអាចធ្វើទៅបានលុះត្រាតែមានការគាំទ្រ ពីសមាជិកដែលចូលរួមយ៉ាងតិចពីរភាគបី (២/៣)។

### ៤.១.៣. ការដឹកនាំកិច្ចប្រជុំ និងកំណត់ហេតុ

រាល់កិច្ចប្រជុំទាំងអស់ត្រូវធ្វើឡើងក្រោមការដឹកនាំរបស់សហប្រធាន ដែលជាប្រធានក្រុមប្រឹក្សាយោបល់ និងលេខាធិការដ្ឋានរេដបូក។

### ៤.១.៤. កំណត់ហេតុនៃកិច្ចប្រជុំ

រាល់កំណត់ហេតុនៃកិច្ចប្រជុំនីមួយៗ ត្រូវបានចែកជូនដល់សមាជិកទាំងអស់ ក្នុងរង្វង់ ៧ ថ្ងៃ កំឡុងថ្ងៃធ្វើការងារ ដើម្បីធ្វើការផ្ដល់មតិ និងកែប្រែ លើសេចក្ដីសម្រេចនៃកិច្ចប្រជុំ មុនពេលផ្ញើជូនសហប្រធានដើម្បីសរុប ឬកែលម្អ និងចុះហត្ថលេខា។ កំណត់ហេតុទាំងអស់នេះ នឹងត្រូវបានរក្សាទុកនៅស្នាក់ការ របស់លេខាធិការដ្ឋានរេដបូក និងផ្ញើជូនសមាជិកក្រុមប្រឹក្សាយោបល់ទាំងអស់។

### ៤.១.៥. ប្រភេទនៃកិច្ចប្រជុំ

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាយោបល់ចែកចេញជាបីប្រភេទ៖

#### ៤.១.៥.១. កិច្ចប្រជុំសាមញ្ញ

កិច្ចប្រជុំសាមញ្ញនេះត្រូវបានធ្វើឡើងរៀងរាល់ពីរខែម្ដង ដើម្បីពិនិត្យទៅលើកិច្ចការងារ និងផែនការអនុវត្តន៍ របស់ក្រុមការងាររេដបូក ដោយពិភាក្សាទៅលើបញ្ហា ឬ អនុសាសន៍រួមដែលតំណាងក្រុមប្រឹក្សាយោបល់ នីមួយៗទទួលបានពីក្រុមរបស់ខ្លួន។ កិច្ចប្រជុំនេះ ក៏អាចជាវេទិកាសម្រាប់ផ្ដល់នូវព័ត៌មានថ្មីៗពីសកម្មភាព របស់សមាជិក និងពិនិត្យមើលទៅលើបញ្ហាទូទៅរបស់ក្រុម។

- កិច្ចប្រជុំពីរខែម្ដង ត្រូវបានបើកចំហ ចំពោះសមាជិកទាំងអស់របស់ក្រុមប្រឹក្សា យោបល់។ សមាជិកទាំងឡាយអាចលើកជាសំណើទៅកាន់ប្រធាន ដើម្បីអញ្ជើញអង្គការ ស្ថាប័ន ឬ អ្នកជំនាញឯករាជ្យមកធ្វើបទបង្ហាញ ជាអ្នកសង្កេតការ ឬ ជាវាគ្មិន។
- ក្នុងករណីដែលត្រូវធ្វើការសម្រេចចិត្តលើបញ្ហា ឬ ការងារណាមួយ សមាជិក ឬ អ្នកតំណាងក្រុមនីមួយៗ អាចអនុញ្ញាតឲ្យបោះឆ្នោតមួយសម្លេង។
- សេក្តីជូនដំណឹងអំពីកិច្ចប្រជុំ ត្រូវបានចែកជូនតាមរយៈអ៊ីម៉ែល និង/ឬ ទូរស័ព្ទ ដោយប្រធានក្រុមប្រឹក្សាយោបល់ (ដែលអាចមានការសម្របសម្រួលពីលេខាធិការដ្ឋានរេដបូក តាមការស្នើសុំ) ជាអប្បបរិមា ១៤ថ្ងៃ មុនកិច្ចប្រជុំកើតឡើង។

### ៤.១.៥.២. កិច្ចប្រជុំវិសាមញ្ញ

កិច្ចប្រជុំវិសាមញ្ញនេះត្រូវបានធ្វើឡើងដើម្បីដោះស្រាយនូវរាល់បញ្ហាបន្ទាន់ឬបញ្ហាសំខាន់ដែលជះឥទ្ធិពលដល់ការអនុវត្តការងាររបស់ក្រុមប្រឹក្សាយោបល់និង/ឬកម្មវិធីវេជបូកកម្ពុជា។ កិច្ចប្រជុំវិសាមញ្ញ អាចធ្វើទៅបានលុះត្រាតែៈ

- មានការដាក់សំណើជាលាយលក្ខណ៍អក្សររបស់សមាជិក យ៉ាងហោចណាស់ហាសិបភាគរយបូកមួយ (៥០%+១) នៃសមាជិកក្រុមប្រឹក្សាយោបល់ទាំងអស់ ទៅកាន់ប្រធានក្រុមប្រឹក្សាយោបល់។
- មានការជូនដំណឹងពីប្រធានក្រុមប្រឹក្សាយោបល់ ដល់លេខាធិការដ្ឋានវេជបូកកម្ពុជាក្នុងកំឡុងមួយសប្តាហ៍យ៉ាងតិច។
- មានការយល់ព្រមពីលេខាធិការដ្ឋានវេជបូកកម្ពុជា។
- មានការកោះអញ្ជើញប្រជុំពីប្រធានក្រុមប្រឹក្សាយោបល់ ទៅសមាជិកយ៉ាងហោចណាស់មួយសប្តាហ៍មុនថ្ងៃប្រជុំ។ ចំពោះកិច្ចការសម្ងាត់ មានតែសេចក្តីសម្រេចចុងក្រោយប៉ុណ្ណោះ នឹងត្រូវបានដាក់បញ្ចូលទៅក្នុងកំណត់ហេតុ និងធ្វើការចែកជូនសមាជិកនៃក្រុម។

### ៤.១.៥.៣. កិច្ចប្រជុំប្រចាំឆ្នាំ

កិច្ចប្រជុំប្រចាំឆ្នាំនេះត្រូវបានធ្វើឡើង ដើម្បីពិនិត្យទៅលើវឌ្ឍនភាព និងប្រសិទ្ធិភាពនៃដំណើរការនៃការធ្វើការងារ ភាពជោគជ័យ និងភាពប្រឈមនៃក្រុមប្រឹក្សាយោបល់។ កិច្ចប្រជុំនេះអាចធ្វើទៅបានលុះត្រាតែៈ

- សេចក្តីជូនដំណឹងដល់សមាជិកក្រុមប្រឹក្សាយោបល់ទាំងអស់ ពីកិច្ចប្រជុំប្រចាំឆ្នាំនេះត្រូវបានធ្វើឡើងយ៉ាងហោចណាស់ ៣០ថ្ងៃ មុនកិច្ចប្រជុំ ជាមួយនឹងការដាក់ស្នើបញ្ចូលនូវរបៀបវារៈ។
- ប្រធានបានជូនដំណឹងដល់តំណាងក្រុមនីមួយៗ ដើម្បីរៀបចំបង្ហាញពីវឌ្ឍនភាព និង ប្រសិទ្ធិភាពនៃដំណើរការនៃការធ្វើការងារ ភាពជោគជ័យ និងភាពប្រឈមនៃក្រុមប្រឹក្សាយោបល់។

### ៤.២. របាយការណ៍ប្រចាំឆ្នាំ

- របាយការណ៍សកម្មភាពប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាយោបល់៖ សមាជិកតំណាងក្រុមនីមួយៗ នឹងត្រូវធ្វើការសង្ខេបព័ត៌មាន និង/ឬ សកម្មភាពរបស់ខ្លួន ហើយផ្ញើជូនប្រធាននៃក្រុមប្រឹក្សាយោបល់ នឹងត្រូវធ្វើការសង្ខេបព័ត៌មាន និង/ឬ សកម្មភាពរបស់ខ្លួន ហើយផ្ញើជូនប្រធាននៃក្រុមប្រឹក្សាយោបល់ ក្នុងការរៀបចំចងក្រង ដោយមានការជួយគាំទ្រពីលេខាធិការដ្ឋាន និងផ្សព្វផ្សាយជាសាធារណៈក្នុងឆ្នាំនីមួយៗ។
- របាយការណ៍ប្រចាំឆ្នាំ ត្រូវដាក់បញ្ចូលនូវសេចក្តីសង្ខេបសកម្មភាព និងរបាយការណ៍អនុវត្តន៍ ក៏ដូចជាព័ត៌មានផ្សេងៗទៀត ដែលបានអនុវត្ត ដោយក្រុមប្រឹក្សាយោបល់។
- របាយការណ៍ប្រចាំឆ្នាំ នឹងត្រូវបានអនុម័តយល់ព្រមពីសមាជិកក្រុមប្រឹក្សាយោបល់ និងចុះ ហត្ថលេខា ដោយប្រធានក្រុមប្រឹក្សាយោបល់។

### ៤.៣. ការរក្សាកំណត់ត្រារបស់ក្រុមប្រឹក្សាយោបល់

រាល់កំណត់ត្រាសំខាន់ៗរបស់ក្រុមប្រឹក្សាយោបល់ ត្រូវរក្សាទុកនៅលេខាធិការដ្ឋានរេដបូកកម្ពុជា។ ឯកសារសំខាន់ៗ រួមមាន៖ ឯកសារបង្កើតក្រុមប្រឹក្សាយោបល់ ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាយោបល់ កំណត់ហេតុប្រជុំ គម្រោងសំណើរ របាយការណ៍អនុវត្តន៍ការងារ របាយការណ៍ប្រចាំឆ្នាំ កិច្ចសន្យា និងឯកសារសំខាន់ៗផ្សេងទៀត ដែលកំណត់ដោយក្រុមប្រឹក្សាយោបល់នៃកម្មវិធីរេដបូកកម្ពុជា។

# ប្រការ ៥៖ ការវាយតម្លៃ និងលំហូរព័ត៌មានរបស់សមាជិកក្រុមប្រឹក្សាយោបល់នៃកម្មវិធីរេដបូកកម្ពុជា

### ៥.១. ការវាយតម្លៃសមាជិកក្រុមប្រឹក្សាយោបល់

- ការវាយតម្លៃ គឺជាវិធីមួយដើម្បីពិនិត្យទៅលើលទ្ធផលនៃការបំពេញការងាររបស់សមាជិកក្រុមប្រឹក្សាយោបល់ម្នាក់ៗ

- ការវាយតម្លៃ ត្រូវធ្វើឡើងជារៀងរាល់ឆ្នាំ ហើយទម្រង់នៃការវាយតម្លៃ គឺមានលក្ខណៈសាមញ្ញ និងស្វ័យតវាយតម្លៃដោយខ្លួនឯង។
- ប្រធានក្រុមប្រឹក្សាយោបល់ នឹងជួយសម្របសម្រួលលើដំណើរការវាយតម្លៃប្រចាំឆ្នាំ ដោយផ្អែកទៅតាមគោលបំណងនៃការបំពេញការងារ ដែលបានព្រមព្រៀង។

**៥.២. លំហូរព័ត៌មានរបស់សមាជិកក្រុមប្រឹក្សាយោបល់**

ទំនាក់ទំនងគឺអាចធ្វើឡើងតាមរយៈមធ្យោបាយផ្សេងៗ៖

- កិច្ចពិភាក្សា ឬ កិច្ចប្រជុំ
- ការផ្ញើសារអេឡិចត្រូនិច ឬ តាមសំបុត្រ
- ការទូរស័ព្ទទំនាក់ទំនង
- គេហទំព័រ (កម្មវិធីវេដបូកកម្ពុជា)

# ប្រការ ៦៖ វិសោធនកម្មនៃការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាយោបល់នៃ កម្មវិធីវេដបូកកម្ពុជា

សំណើធ្វើវិសោធនកម្មនៃការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាយោបល់នៃកម្មវិធីវេដបូកកម្ពុជាអាចធ្វើឡើងបានលុះត្រាតែ មានសមាជិកក្រុមប្រឹក្សាយោបល់ចំនួនបី(០៣)នាក់យ៉ាងតិចបានស្នើឡើង ដោយសរសេរជាលាយលក្ខណ៍អក្សរផ្ញើជូន ប្រធានក្រុមប្រឹក្សាយោបល់ ដើម្បីដាក់បញ្ចូលទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំ។ វិសោធនកម្មនេះអាចធ្វើតាមរយៈកិច្ចប្រជុំប្រចាំពីរខែ ឬ ប្រជុំវិសាមញ្ញ របស់ក្រុមប្រឹក្សាយោបល់។

# ប្រការ ៧៖ អវសានប្បញ្ញត្តិ

ប្រធាន សហប្រធាន លេខា និងសមាជិក ក្រុមប្រឹក្សាយោបល់នៃកម្មវិធីរេដបូកកម្ពុជា ត្រូវអនុវត្តតាមភារកិច្ចរៀងៗខ្លួន។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាយោបល់នៃកម្មវិធីរេដបូកកម្ពុជា មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះ ហត្ថលេខាដោយប្រធាននៃក្រុមប្រឹក្សាយោបល់កម្មវិធីរេដបូកកម្ពុជាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៥

**ប្រធានក្រុមប្រឹក្សាយោបល់នៃកម្មវិធីរេដបូកកម្ពុជា**

**យាន ដូណាល់**